# ជួបភ័ក្រជំពាក់ស្នេហ៍

*កាកគតិ*

ដូចព្រះលោចារ    ដូចជាទេវតា    ចារជាគូស្នេហ៍
មិនដែលជួបសោះ    ម្ល៉ោះកើតពីម៉ែ    ពេលនេះស្រាប់តែ
ស្នេហ៍រឹតរុំទ្រូង។
ឃើញភ្លែតស្នេហ៍ភ្លាម    ក្តៅកស្លរឈោម    ដូចបៀបភ្លើងធ្យូង
បេះដូងបែកធ្លាយ    ធ្លុះព្រោះគេទូង    រយលានអន្លូង
រូងរុករោចរើ។
ផ្កាឆើតក្លិនស្នេហ៍    ឃើញភ្លាមចង់ថែ    ក្បែរស្រស់ជំទើ
ដើរពីក្រោយអូន    សូន្យដូចជាភ្លើ    ដើរមើលៗ
ភ្លេចចូលសាលា។
ស៊ូឈប់មួយពេល    ចង់ដឹងមាសមេ    រៀនបន្ទប់ណា
តាមមើលឆោមស្រស់    លុះដឹងកិច្ចការ    អូនរៀនថ្នាក់ណា
ទើបទ្រូងបងស្បើយ។
ដឹងហើយជាក់ច្បាស់    តែចិត្តមិនផ្លាស់    ភ្លេចអូនបានឡើយ
នៅមិនបាត់ហ្មង    មិនឆ្លងដល់ត្រើយ    ចិត្តជាប់កៀកកើយ
ស្គាលស្និទ្ធស្នេហា។
ចេញលេងម្តងៗ    មិននៅសាសង    រឿងឥតបានការ
នឹងមិត្តរួមថ្នាក់    ដាក់ចិត្តយាត្រា    មើលមុខជីវ៉ា
តាមកៀនបង្អួច។

តាមមើលរាល់ថ្ងៃ មើលលុះស្រមៃ ថ្ងៃគេចមិនរួច
ជាប់ស្នេហ៍នួនល្អង បងសែនព្រឺព្រួច ឆ្កួតព្រោះតំនួច
គួចស្នេហ៍អូនហើយ។

ភ្នំពេញ ថ្ងៃទី០៨មេសា២០០៥
សូយ ឡូត